ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ....................សហវ.......

# របាយការណ៍

# និន្នាការសេដ្ឋកិច្ច-សង្គម

## ប្រចាំខែ មិថុនា ឆ្នាំ ២០២៤

# Socio-Economic Trends Report

## June 2024

រៀបចំដោយ
នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច
អគ្គនាយកដ្ឋានគោលនយោបាយ
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
Phone: (+855) 23 890 666
mef.cabinet@mef.gov.kh

# មាតិកា


ទំព័រ

**ខ្លឹមសារសង្ខេប /Executive summary** **១**

**១. និន្នាការសេដ្ឋកិច្ចកម្ពុជា /Cambodia economic trends** **៤**

១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ /Consumer price index ៤

១.២. វិស័យពាណិជ្ជកម្ម /Trade ៥

១.៣. វិស័យវិនិយោគឯកជន /Private investment ៨

១.៤. វិស័យទេសចរណ៍ក្នុងតំបន់អង្គរ /Tourism in Angkor Park ៩

១.៥. វិស័យសំណង់ /Construction ១០

**២. និន្នាការថ្លៃទំនិញសំខាន់ៗ /Commodity prices** **១១**

២.១. ថ្លៃប្រេង (Crude oil price: Brent, Dubai, WTI) ១១

២.២. ថ្លៃអង្ករ (Rice price: 5%, 25% broken) ១២

**៣. ឧបសម្ព័ន្ធ** **១៤**

## ខ្លឹមសារសង្ខេប / Executive summary

*ស្ថានភាពសេដ្ឋកិច្ច-សង្គមសំខាន់ៗ ក្នុងខែមិថុនា ឆ្នាំ២០២៤ នេះ មាននិន្នាការដូចខាងក្រោម៖*

១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្មនៅរាជធានីភ្នំពេញ ក្នុងខែមិថុនា ឆ្នាំ២០២៤ កើន ០,០១% ធៀបនឹងខែមុន និងកើន០,៧% ធៀបនឹងខែមិថុនា ឆ្នាំ២០២៣។ សន្ទស្សន៍ថ្លៃក្រុមទំនិញប្រើប្រាស់ និងសេវាកម្ម ដែលមានកំណើនក្នុងខែរួមមាន៖ ក្រុមសុខាភិបាល កើន ២,៣%, ក្រុមភោជនីយដ្ឋាន កើន ០,៦%, និងក្រុមសម្លៀកបំពាក់ និងស្បែកជើង កើន ០,៥%។ ជាមួយគ្នានេះ ក្រុមសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្ម ដែលកើនឡើងធៀបនឹង ខែមិថុនា ឆ្នាំ២០២៣ រួមមាន៖ ក្រុមសុខាភិបាល កើន ២,៦%, ក្រុមសម្លៀកបំពាក់ និងស្បែកជើង កើន ២,៥% និងក្រុមការសិក្សា កើន ២,៥%។

២. ទំហំពាណិជ្ជកម្មដកមាសក្នុងខែមិថុនា ឆ្នាំ២០២៤ មានទំហំ ៤ ៧៥៣ លានដុល្លារ កើន ១,៨% ធៀបនឹងខែមុន, ក្នុងនោះ ការនាំចេញ មានទំហំ ២ ២២៣ លានដុល្លារ កើន ៧,៥% និងការនាំចូល មានទំហំ ២ ៥៣០ លានដុល្លារ ថយ ២,៨%។ បើគិតត្រឹមឆមាសទី១ ទំហំពាណិជ្ជកម្មដកមាស មានទំហំប្រមាណ ២៦ ០៩៣ លានដុល្លារ កើន ១២,៧% បើធៀបនឹងឆមាសទី១ ឆ្នាំមុន។ ជាមួយគ្នានេះ តុល្យភាពជញ្ជីងពាណិជ្ជកម្ម (នាំចេញ-នាំចូល) ក្នុងឆមាសទី១ ឆ្នាំ២០២៤ បានបង្ហាញពីឱនភាពប្រមាណជាង ១ ៥៣១ លានដុល្លារ ក៏ដោយសារកំណើននៃទំហំនាំចូល វត្ថុធាតុដើមកាត់ដេរ គ្រឿងបរិក្ខារសំណង់ ប្រេងឥន្ធនៈ និងផលិតផលមួយចំនួនទៀតដែលជាធាតុចូលសម្រាប់គាំទ្រដល់មូលដ្ឋានផលិតកម្ម។

៣. ក្នុងខែមិថុនា ឆ្នាំ២០២៤ ចំនួនភ្ញៀវទេសចរបរទេសចូលទស្សនាតំបន់អង្គរមានការធ្លាក់ចុះធៀបនឹងខែឧសភា ឆ្នាំ២០២៤ ដោយសារកត្តារដូវកាលទេសចរណ៍ថមថយ (Low-Season)។ ជាក់ស្តែង ក្នុងខែមិថុនា ឆ្នាំ២០២៤ តំបន់អង្គរទទួលបានភ្ញៀវទេសចរបរទេសចំនួន ៤៩ ៦៩២ នាក់ ធ្លាក់ ២,៣% និងចំណូលពីការលក់ប័ណ្ណពីគ្រឹះស្ថានអង្គរមានប្រមាណ ២,១៥ លានដុល្លា ធ្លាក់ ៦,១% ធៀបនឹងខែឧសភា ឆ្នាំ២០២៤។ ប៉ុន្តែ ក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២៤ ចំនួនភ្ញៀវទេសចរបរទេសចូលទស្សនាតំបន់អង្គរ កើន ៣៥,៣% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៣។

៤. យោងតាមទិន្នន័យខែមិថុនា ឆ្នាំ២០២៤ ចំនួនគម្រោងសាងសង់ និងទំហំផ្ទៃក្រឡាគម្រោងសាងសង់ បានបន្តរើបឡើងវិញជាបន្តបន្ទាប់ធៀបនឹងខែមុន។ ក្នុងខែមិថុនា ឆ្នាំ២០២៤ គម្រោងសំណង់ទទួលបានការអនុញ្ញាតសាងសង់សរុបមាន ៣១២ គម្រោង កើន ៣៥,១%, មានផ្ទៃក្រឡា ១ ៨៦៩ ពាន់ម៉ែត្រការ៉េ កើន ៣៦,១%, ដោយប្រើប្រាស់ទុន ៧២៥,០ លានដុល្លារ និងថយ ២,០% ធៀបនឹងខែមុន។

៥. ស្ថានភាពគម្រោងវិនិយោគឯកជនដែលទទួលបានការអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងខែមិថុនា ឆ្នាំ២០២៤ មានកំណើនល្អប្រសើរ។ ជាក់ស្តែង ចំនួនគម្រោងវិនិយោគក្នុងខែមិថុនា ឆ្នាំ២០២៤ មាន ៣៧ គម្រោង ដែលបានប្រើប្រាស់ទុនវិនិយោគសរុបចំនួន ៤៩៨ លានដុល្លារ កើន ១០២% និងបង្កើតការងារថ្មីប្រមាណ ២២ ៩៥១ កន្លែង កើន ៣៨% ធៀបនឹងខែមុន។

៦. ក្នុងខែមិថុនា ឆ្នាំ២០២៤ ថ្លៃប្រេងឆៅអន្តរជាតិជាមធ្យម និងថ្លៃប្រេងឥន្ធនៈក្នុងស្រុកជាមធ្យម ថយ ០,៣% និង ១,៨% រៀងគ្នា ខណៈដែល ថ្លៃអង្ករអន្តរជាតិជាមធ្យម កើន ០,៣% និងថ្លៃអង្ករក្នុងស្រុកជាមធ្យម ប្រហាក់ប្រហែល

នឹងខែមុន។ គួរកត់សម្គាល់ដែរថា ទោះមានការថយចុះតិចតួចក្នុងខែមិថុនា ប៉ុន្តែក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២៤ ថ្លៃប្រេងឆៅអន្តរជាតិ និងថ្លៃអង្ករអន្តរជាតិ កើន ៥,៥% និង ២៤,៩% រៀងគ្នា ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៣ ស្របពេលដែល ថ្លៃប្រេងឥន្ធនៈក្នុងស្រុក និងថ្លៃអង្ករក្នុងស្រុក កើន ០,១% និង ១១,៤% រៀងគ្នា។ ការកើនឡើងថ្លៃប្រេងឥន្ធនៈក្នុងស្រុក អាចបណ្តាលមកពីការឡើងថ្លៃប្រេងឆៅអន្តរជាតិ ខណៈដែល ការកើនឡើងថ្លៃអង្ករក្នុងស្រុក អាចបណ្តាលមកពីបញ្ហាអាកាសធាតុ និងការបន្តការបន្ថយពន្ធលើការនាំចេញអង្ករទៅទីផ្សារអន្តរជាតិ។ យ៉ាងណាមិញ ថ្លៃប្រេងឥន្ធនៈ និងថ្លៃអង្ករក្នុងស្រុកជាមធ្យម មិនទាន់ឡើងដល់កម្រិតគួរឱ្យបារម្ភនៅឡើយទេ។

*សូចនាករសេដ្ឋកិច្ចសំខាន់ៗក្នុងខែមិថុនា និងរយៈពេល ៦ខែ ឆ្នាំ២០២៤ បានបង្ហាញពីសញ្ញាកាន់តែល្អជាបន្តបន្ទាប់ ជាពិសេសលើវិស័យពាណិជ្ជកម្មអន្តរជាតិ ជាមួយនឹងសន្ទុះនៃការនាំចេញ ដែលជំរុញដោយភាពជាដៃគូអន្តរជាតិ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មជាច្រើន។ កិច្ចព្រមព្រៀងទាំងនេះ បាននិងកំពុងជំរុញទាំងការនាំចេញ និងវិនិយោគ ដែលបានរួមចំណែកជាសារវន្តដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ ជាមួយគ្នានេះ ស្ថានភាពអតិផរណា កំពុងវិលត្រលប់មកស្ថានភាព ប្រសើរឡើងវិញ, ស្របពេលដែល សកម្មភាពសាងសង់បានលេចឡើងនូវសញ្ញានៃការងើបឡើង។ វិស័យពាណិជ្ជកម្មអន្តរជាតិ អាចនឹងមានសន្ទុះកំណើនល្អនៅខែបន្ទាប់ ជាពិសេស ការនាំចេញផលិតផលវាយនភណ្ឌទៅកាន់ទីផ្សារលោកខាងលិចនារដូវរងាខាងមុខ។ ផ្អែកលើការតាមដានជាប់ជាប្រចាំទាំងសេដ្ឋកិច្ចក្នុងប្រទេស និងសេដ្ឋកិច្ចសកល បង្ហាញថាសកម្មភាពសេដ្ឋកិច្ចកម្ពុជា នៅបន្តចលនការងើបឡើងជាពិសេសក្នុងវិស័យសេវាកម្ម និងពាណិជ្ជកម្ម ។*

| តារាង ១៖ ស្ថិតិសង្ខេបសេដ្ឋកិច្ចតាមវិស័យ ប្រចាំខែមិថុនា ឆ្នាំ២០២៤ | | | | | | |
|---|---|---|---|---|---|---|
| | សូចនាករតាមវិស័យ | ឯកតា | តម្លៃ | កើន/ថយ | | |
| | | | | ខែមុន | មិថុនា ឆ្នាំមុន | ៦ខែ ដើមឆ្នាំមុន |
| I | **សន្ទស្សន៍ថ្លៃ និងថ្លៃទំនិញ** | | | | | |
| | -សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្មនៅរាជធានីភ្នំពេញ | សន្ទស្សន៍ | 203.56 | 0.01% | 0.70% | 0.26% |
| | -សន្ទស្សន៍ថ្លៃម្ហូបអាហារ | សន្ទស្សន៍ | 257.42 | -0.32% | 0.80% | 0.40% |
| | -ថ្លៃប្រេងសាំង | រៀល/លីត្រ | 4,167 | -3.47% | -0.40% | 0.52% |
| | -ថ្លៃប្រេងម៉ាស៊ូត | រៀល/លីត្រ | 4,067 | 0.00% | 4.27% | -0.40% |
| | -ថ្លៃអង្ករផ្កាម្លិះ | រៀល/គ.ក | 4,047 | -0.30% | 6.16% | 6.49% |
| | -ថ្លៃអង្ករផ្កាខ្ញី | រៀល/គ.ក | 3,355 | 1.35% | 10.92% | 20.91% |
| | -ថ្លៃអង្ករនាងមិញ | រៀល/គ.ក | 2,976 | -2.86% | 8.21% | 8.43% |
| | -ថ្លៃសាច់ត្រី | រៀល/គ.ក | 11,689 | 5.27% | 5.44% | 6.46% |
| | -ថ្លៃសាច់ជ្រូក | រៀល/គ.ក | 23,642 | -2.76% | 2.24% | 7.04% |
| | -ថ្លៃប្រេងឆៅ (Brent) | USD/BBL | 82.56 | 0.68% | 10.24% | 5.22% |
| | -ថ្លៃប្រេងឆៅ (WTI) | USD/BBL | 78.89 | 0.10% | 12.33% | 5.30% |
| | -ថ្លៃអង្ករថៃ (ប្រភេទអង្ករបាក់ ៥%) | USD/MT | 632.00 | 0.64% | 22.96% | 24.55% |
| | -ថ្លៃអង្កររៀតណាម (ប្រភេទអង្ករបាក់ ៥%) | USD/MT | 561.63 | -1.12% | 10.50% | 27.42% |
| II | **ពាណិជ្ជកម្មកម្ពុជា** | | | | | |
| | ***ការនាំចេញទំនិញសរុប (ដកមាស)*** | **លានដុល្លារ** | 2,223.02 | 7.54% | 1.38% | 12.56% |
| | -កម្មន្តសាលកាត់ដេរ | លានដុល្លារ | 1,262.10 | 6.28% | 4.05% | 16.89% |
| | -កម្មន្តសាលមិនមែនកាត់ដេរ | លានដុល្លារ | 810.79 | 18.54% | -0.51% | -1.00% |
| | -ផលិតផលកសិកម្ម* | លានដុល្លារ | 150.12 | -23.27% | -8.95% | 27.21% |
| | ***ការនាំចូលសរុប (ដកមាស)*** | **លានដុល្លារ** | 2,530.25 | -2.76% | 19.35% | 12.82% |
| | -ប្រេងឥន្ធនៈ | លានដុល្លារ | 242.17 | -16.40% | 21.33% | 29.56% |
| | -វត្ថុធាតុដើមកាត់ដេរ | លានដុល្លារ | 484.06 | -18.95% | 19.84% | 21.22% |
| | -គ្រឿងសំណង់** | លានដុល្លារ | 209.95 | -8.33% | 24.52% | 23.32% |
| | -វត្ថុធាតុដើមកសិកម្ម (ជីកសិកម្ម) | លានដុល្លារ | 40.60 | 10.99% | 18.10% | 14.61% |
| | -គ្រឿងហូបចុក (Food stuff) | លានដុល្លារ | 80.27 | 4.63% | 30.48% | 18.39% |
| III | **ទេសចរណ៍** | | | | | |
| | -ភ្ញៀវទេសចរបរទេសទិញប័ណ្ណពីគ្រឹះស្ថានអង្គរ | នាក់ | 49,692.00 | -2.33% | 21.16% | 35.30% |
| | -ចំណូលពីការលក់ប័ណ្ណរបស់គ្រឹះស្ថានអង្គរ | ដុល្លារ | 2,150,804.00 | -6.05% | 18.72% | 36.25% |
| IV | **សាងសង់** | | | | | |
| | -ចំនួនគម្រោងដែលទទួលបានការអនុញ្ញាតសាងសង់ | គម្រោង | 312.00 | 35.06% | -19.17% | -11.20% |
| | -ផ្ទៃក្រឡាសាងសង់ | ម៉ែត្រការ៉េ | 1,868,720.00 | 36.06% | 44.91% | -9.83% |
| | -ទំហំទឹកប្រាក់សាងសង់ | លានដុល្លារ | 724,954,180.00 | -2.00% | 48.31% | -8.10% |
| V | **គម្រោងវិនិយោគ** | | | | | |
| | -គម្រោងវិនិយោគឯកជន | គម្រោង | 37.00 | 48.00% | -2.63% | 68.14% |
| | -ទុនវិនិយោគសរុប | លានដុល្លារ | 498.44 | 102.37% | 9.05% | 194.66% |
| | -កម្លាំងពលកម្មថ្មី | នាក់ | 22,951.00 | 51.60% | -41.83% | 37.97% |

***សម្គាល់*៖** *ផលិតផលកសិកម្ម រួមមាន៖ ស្រូវ, អង្ករ, ដំឡូងមី, ពោត, សណ្ដែក, ចេក, ស្វាយ, ស្វាយចន្ទី, កៅស៊ូ, ស្ករ, ផលិតផលជលផល និងផលិតផលកសិកម្មផ្សេងទៀត

**សំណង់ រួមមាន៖ គ្រឿងបរិក្ខារសំណង់, ស៊ីម៉ង់ត៍ និងដែកថែប។

# ១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia economic trends

## ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index

តាមរយៈទិន្នន័យផ្លូវការពីវិទ្យាស្ថានជាតិស្ថិតិ ក្នុងខែមិថុនា ឆ្នាំ២០២៤ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្ម នៅរាជធានីភ្នំពេញ កើន ០,០១% ធៀបនឹងខែមុន និង កើន ០,៧% ធៀបនឹងខែមិថុនា ឆ្នាំ២០២៣។ សន្ទស្សន៍ថ្លៃក្រុមទំនិញប្រើប្រាស់ និងសេវាកម្ម ដែលមានកំណើនក្នុងខែរួមមាន ៖ ក្រុមសុខាភិបាល កើន ២,៣%, ក្រុមភោជនីយដ្ឋាន កើន ០,៦%, និងក្រុមសម្លៀកបំពាក់ និងស្បែកជើង កើន ០,៥%។

ជាមួយគ្នានេះ ក្រុមសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្ម ដែលមានការកើនឡើងគួរឱ្យកត់សម្គាល់ ធៀបនឹងខែមិថុនា ឆ្នាំ២០២៣ រួមមាន៖ ក្រុមសុខាភិបាល កើន ២,៦%, ក្រុមសម្លៀកបំពាក់ និងស្បែកជើង កើន ២,៥%, និងក្រុមការសិក្សា កើន ២,៥%។ ទន្ទឹមនេះ ក្រុមអាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង កើន ០,៨% ធៀបនឹងខែមិថុនា ឆ្នាំ២០២៣ ក្នុងនោះ សន្ទស្សន៍ថ្លៃអង្ករ កើន ០,៤% និងសន្ទស្សន៍ថ្លៃត្រីទឹកសាប និងត្រីសមុទ្រ កើន ០,៤% ដោយឡែក សន្ទស្សន៍ថ្លៃក្រុមសាច់ ថយ ០,២%។ ក្នុងខែមិថុនា ឆ្នាំ២០២៤ សន្ទស្សន៍ថ្លៃក្រុមដឹកជញ្ជូន ថយ ០,៣% ធៀបនឹងខែមិថុនា ឆ្នាំ២០២៣ ខណៈដែល ថ្លៃសាំងធម្មតា ថយ ០,៤% ប៉ុន្តែ ថ្លៃប្រេងម៉ាស៊ូត កើន ៤,៣%។

ក្រាហ្វិក ១៖ អត្រាអតិផរណានៅរាជធានីភ្នំពេញ ខែធៀបខែ និងឆ្នាំធៀបឆ្នាំ




ក្រាហ្វិក ២៖ សន្ទស្សន៍ថ្លៃម្ហូបអាហារ (ឆ្នាំធៀបឆ្នាំ)




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ*

**ក្រាហ្វិក ៣៖ សន្ទស្សន៍ថ្លៃដឹកជញ្ជូន (ឆ្នាំធៀបឆ្នាំ)**




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងក្រសួងពាណិជ្ជកម្ម*

## ១.២. វិស័យពាណិជ្ជកម្ម / Trade

គិតត្រឹមខែមិថុនា ឆ្នាំ២០២៤ នេះ ទំហំពាណិជ្ជកម្មសរុប សម្រេចបានកំណើនល្អគួរឱ្យកត់សម្គាល់ ទាំងកំណើនធៀបខែមុន ធៀបខែមិថុនាដូចគ្នាឆ្នាំមុន និងធៀបនឹងឆមាសទី១ដូចគ្នាឆ្នាំមុន។ ទំហំពាណិជ្ជកម្ម(ដកមាស) ក្នុងខែមិថុនានេះ មានប្រមាណ ៤ ៧៥៣ លានដុល្លារ កើន ១,៨% ធៀបនឹងខែមុន, និងកើន ១០,២% ធៀបនឹងខែមិថុនាដូចគ្នាឆ្នាំមុន, ខណៈដែលក្នុងឆមាសទី១នេះ មានប្រមាណ ២៦ ០៩៣ លានដុល្លារ កើនដល់ ១២,៧% បើធៀបនឹងឆមាសទី១ ឆ្នាំមុន។ គួរឱ្យកត់សម្គាល់ផងដែរ តុល្យភាពជញ្ជីងពាណិជ្ជកម្ម (នាំចេញ-នាំចូល) ក្នុងឆមាសទី១ ឆ្នាំ ២០២៤ បានបង្ហាញពីឱនភាពប្រមាណជាង ១ ៥៣១ លានដុល្លារធៀបនឹងឆមាសទី១ ឆ្នាំមុន ដោយសារកំណើននាំចូលវត្ថុធាតុដើមកាត់ដេរ គ្រឿងបរិក្ខារសំណង់ ប្រេងឥន្ធនៈ និងផលិតផលមួយចំនួនទៀតដែលជាធាតុចូលសម្រាប់គាំទ្រដល់មូលដ្ឋានផលិតកម្ម។

**ក្រាហ្វិក ៤៖ ស្ថានភាពពាណិជ្ជកម្ម (ដកមាស) គិតត្រឹមខែមិថុនា ឆ្នាំ២០២៤ (គិតជាលានដុល្លារ)**




*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

**ក. ការនាំចេញ៖** ការនាំចេញទំនិញ(ដកមាស) ក្នុងខែមិថុនា ឆ្នាំ២០២៤ នេះ សម្រេចបានកំណើនគួរឱ្យកត់សម្គាល់ ដោយសារកំណើនល្អឡើងវិញនៃការនាំចេញកម្មន្តសាលកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ។ ជាក់ស្តែង ការនាំចេញទំនិញ(ដកមាស) សម្រេចបាន ២ ២២៣ លានដុល្លារ កើនឡើង ៧,៥% ធៀបនឹងខែមុន ដែលទ្រទ្រង់ដោយកំណើនល្អប្រសើរនៃការនាំចេញកម្មន្តសាលកាត់ដេរប្រមាណ ៦,៣% និងកម្មន្តសាលមិនមែនកាត់ដេរប្រមាណ ១៨,៥%។ ចំណែកការនាំចេញកសិផលវិញ បានថមថយនៅក្នុងខែមិថុនា នេះ ប៉ុន្តែនៅតែមានភាពល្អជាងខែមិថុនាឆ្នាំមុនប្រមាណ ១,៤%។ គិតត្រឹមឆមាសទី១ ឆ្នាំ២០២៤ ការនាំចេញទំនិញដកមាសមានទំហំ ១២ ២៩៦ លានដុល្លារ កើន ១២,៦% បើធៀបនឹងឆមាសទី១ ឆ្នាំមុន។

**ក្រាហ្វិក ៥៖ ទំហំទឹកប្រាក់នាំចេញដកមាសគិតត្រឹមខែមិថុនា ឆ្នាំ២០២៤ (គិតជាលានដុល្លារ)**




*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

នៅក្នុងខែមិថុនា ឆ្នាំ២០២៤ ការនាំចេញទៅកាន់ទីផ្សារសំខាន់ៗ ហាក់បានបង្ហាញពីការធ្លាក់ចុះបន្តិចរវាងប្រទេសដែលនៅប៉ែកអាស៊ី ជាពិសេសក្នុងតំបន់អាស៊ាន និងចិន ខណៈដែលការនាំចេញជារួមក្នុងឆមាសទី១នេះ មានកំណើនល្អប្រសើរទៅគ្រប់បណ្តាទីផ្សារសំខាន់ៗ។ ជាក់ស្តែង ក្នុងខែមិថុនា ឆ្នាំ២០២៤ ការនាំចេញទៅកាន់ទីផ្សារក្នុងតំបន់អាស៊ាន ចិន និងជប៉ុន បានធ្លាក់ចុះក្នុងរង្វង់ ១៥,៩%, ៧,៩% និង០,៥ រៀងគ្នា ដោយសារការនាំចេញទៅប្រទេសទាំងនេះភាគច្រើនជាទំនិញកសិផល ប៉ុន្តែគិតត្រឹមឆមាសទី១ ឆ្នាំ២០២៤ ការនាំចេញទៅកាន់ទីផ្សារតំបន់អាស៊ានមានទំហំ ២ ៦៨៧ លានដុល្លារ កើន ៨,៣%, ទីផ្សារអឺរ៉ុប មានទំហំ ១ ៩៩៥ លានដុល្លារ កើន ៩,៦%, ទីផ្សារអាម៉េរិកមានទំហំ ៤ ៤០១ លានដុល្លារ កើន ៣,៩%, ទីផ្សារចិន មានទំហំ ៨១៥ លានដុល្លារ កើន ១៤,២%, ទីផ្សារជប៉ុនមានទំហំ ៦២៩ លានដុល្លារ កើន១៥,៤%, ទីផ្សារអង់គ្លេស មានទំហំ ៤២៧ លានដុល្លារ កើន ១៨,៤%, និងទីផ្សារប្រទេសផ្សេងទៀត មានទំហំ ១ ៤៧៤ លានដុល្លារ កើនឡើង ១២,៧% ធៀបនឹងឆមាសទី១ ឆ្នាំមុន។

*ក្រាហ្វិក ៦៖ ទីផ្សារអាមេរិក អឺរ៉ុប និងអាស៊ាន បាន ក្លាយជាទីផ្សារនាំចេញធំរបស់កម្ពុជាក្នុងខែមិថុនា*




*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

*តារាង ២. ទំហំទឹកប្រាក់ និងចំណែក% នៃនាំចេញតាមមុខទំនិញសំខាន់ៗ ក្នុងរយៈពេល ៦ខែ ដើមឆ្នាំ២០២៤ (គិតជាលានដុល្លារអាមេរិក)*

| ទំនិញ (គិតជាលានដុល្លារ) | ទំហំទឹកប្រាក់នាំចេញ | សមាមាត្រជាភាគរយ |
|---|---|---|
| វាយនភណ្ឌ | 6,157 | 49.5% |
| កង់ | 162 | 1.3% |
| អង្ករ | 253 | 2.0% |
| ដំឡូងមី | 500 | 4.0% |
| ជ័រកៅស៊ូ | 229 | 1.8% |
| ទំនិញផ្សេងៗ | 4,996 | 40.2% |
| សរុបដកមាស | 12,296 | 98.9% |
| ទំនិញនាំចេញដកមាសមាន ៩៨,៩% នៃទំនិញនាំចេញសរុប | | |

*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

**ខ. <u>ការនាំចូល</u>** ៖ ការនាំចូលទំនិញ(ដកមាស) ក្នុងខែមិថុនា ឆ្នាំ២០២៤ បានធ្លាក់ចុះបន្តិចធៀបនឹងខែមុន ប៉ុន្តែគិតត្រឹមឆមាសទី១ នៅតែសម្រេចបានកំណើនល្អប្រសើរ។ ទំហំការនាំចូលទំនិញដកមាសក្នុងខែមិថុនា ឆ្នាំ២០២៤ សម្រេចបានប្រមាណជាង ២ ៥៣០ លានដុល្លារ ថយ ២,៨% ធៀបនឹងខែមុន ដោយសារ កាលពីខែមុនមានការសម្រុកនាំចូលច្រើននូវទំនិញដែលជាវត្ថុធាតុដើមក្នុងវិស័យកាត់ដេរ និងសំណង់។ គិតត្រឹមឆមាសទី១ ឆ្នាំ២០២៤ ការនាំចូលទំនិញដកមាស សម្រេចបានទំហំទឹកប្រាក់ ១៣ ៧៩៧ លានដុល្លារ កើន ១២,៨% ធៀបនឹងឆមាសទី១ ឆ្នាំមុន។

**ក្រាហ្វិក ៧៖ ទំហំទឹកប្រាក់នាំចូល (ដកមាស) ក្នុងខែមិថុនា (គិតជាលានដុល្លារ) និងកំណើនធៀបខែ ធៀបឆ្នាំ**




*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

ក្នុងខែមិថុនា ឆ្នាំ២០២៤ ការនាំចូលពីទីផ្សារអឺរ៉ុប និងសហរដ្ឋអាមេរិក ចាប់ផ្តើមមាននិន្នាការកើនឡើងវិញ ធៀបនឹងខែមុន។ ជាក់ស្តែង ក្នុងខែមិថុនា ឆ្នាំ២០២៤ ការនាំចូលពីទីផ្សារអឺរ៉ុប មានទំហំ ១៤៣ លានដុល្លារ កើន ១៨៥,១%, និងទីផ្សារសហរដ្ឋអាមេរិក មានទំហំ ៤០ លានដុល្លារ កើន ៣៩,២% ធៀបនឹងខែមុន។ បើគិតត្រឹមរយៈពេល ៦ខែ

ដើមឆ្នាំ២០២៤នេះ ប្រទេសចិន គឺជាទីផ្សារនាំចូលធំទី១ របស់កម្ពុជា ដែលមានទំហំនាំចូលសរុបប្រមាណ ៦ ២១៤ លានដុល្លារ កើន ២០,២%, តំបន់អាស៊ាន គឺជាទីផ្សារនាំចូលធំទី២ មានទំហំ ៥ ៦៦៩ លានដុល្លារ កើន ១៣,៤%, ខណៈដែលទីផ្សារធំៗបន្ទាប់ទៀត រួមមាន អឺរ៉ុប សហរដ្ឋអាម៉េរិក ជប៉ុន និងអង់គ្លេស បានថយក្នុងរង្វង់ ៦,៦%, ៨,៤%, ១,៩%, និង៥៨,៧% រៀងគ្នា ធៀបនឹងរយៈពេល ៦ខែឆ្នាំមុន។

**ក្រាហ្វិក ៨៖ ទីផ្សារចិន, អាស៊ាន និង អឺរ៉ុបបានរួមចំណែកធំក្នុងទីផ្សារនាំចូលសរុបក្នុងខែមិថុនា**




*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

**តារាង ៣. ទំហំទឹកប្រាក់ និងចំណែក% នៃនាំចូលតាមមុខទំនិញសំខាន់ៗ ក្នុងរយៈពេល ៦ខែ ដើមឆ្នាំ២០២៤ (គិតជាលានដុល្លារអាម៉េរិក)**

| ទំនិញ (គិតជាលានដុល្លារ) | ទំហំទឹកប្រាក់នាំចេញ | សមាមាត្រជាភាគរយ |
|---|---|---|
| ក្រណាត់ | 2,710 | 19.4% |
| គ្រឿងសំណង់ | 1,136 | 8.1% |
| យានយន្ត | 582 | 4.2% |
| ប្រេងឥន្ទនៈ | 1,529 | 11.0% |
| ទំនិញផ្សេងទៀត | 7,839 | 56.2% |
| សរុបដកមាស | 13,797 | 98.8% |
| ទំនិញនាំចូលដកមាសមាន ៩៨,៨% នៃទំនិញនាំចូលសរុប | | |

*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

## ១.៣. ស្ថានភាពវិនិយោគ / Investment

នៅក្នុងខែមិថុនា ឆ្នាំ២០២៤ ប្រទេសកម្ពុជាទទួលបានគម្រោងវិនិយោគសរុប ៣៧ គម្រោង ដែលក្នុងនោះគម្រោងក្នុងតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ២១ គម្រោង (គម្រោងថ្មី ១៩ និង គម្រោងពង្រីកផលិតកម្ម ២) និងក្រៅតំបន់សេដ្ឋកិច្ចពិសេសមានគម្រោងថ្មីចំនួន ១៦ គម្រោង។ ការវិនិយោគនេះបានប្រើប្រាស់ទុនប្រមាណ ៤៩៨,៤ លានដុល្លារ និងមានលទ្ធភាពបង្កើតការងារថ្មីចំនួន ២២ ៩៥១ នាក់។ បើប្រៀបធៀបទៅនឹងខែឧសភា ឆ្នាំ២០២៤ ចំនួនគម្រោងកើន ១២ គម្រោង, ខណៈទំហំទុន និង លទ្ធភាពបង្កើតការងារថ្មីកើន ប្រមាណ ១០២,៤%, ៥១,៦% រៀងគ្នា។ ធៀបនឹងខែមិថុនាឆ្នាំមុន ចំនួនគម្រោងវិនិយោគ និងលទ្ធភាពបង្កើតការងារថ្មី ធ្លាក់ ២,៦%(ស្មើនឹង ១ គម្រោង), និង៤១,៨ % រៀងគ្នា ខណៈដែល ទុនវិនិយោគ កើន ៩,១%។

ជាលទ្ធផល ក្នុងរយៈពេល៦ខែដើមឆ្នាំ២០២៤ មានគម្រោងវិនិយោគសរុប ១៩០ គម្រោង, ដែលបានប្រើប្រាស់ទុនសរុប ៣ ២៥៨ លានដុល្លារ និងលទ្ធភាពបង្កើតការងារថ្មី មាន ១៦៨ ៥៧២ កន្លែង។ បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៣ ចំនួនគម្រោងវិនិយោគ កើនឡើង ៦២ គម្រោង (ស្មើនឹង ៦៨,១%), ទុនវិនិយោគ កើនឡើង ១៩៤,៧%(ស្មើនឹង ២ ១១១ លានដុល្លារ), ការងារកើនឡើង ៧៦ % (ស្មើនឹង ៦២ ៨៧៩ ការងារ) ។

ក្រាហ្វិក ៩៖ ទុនវិនិយោគតាមវិស័យ ៦ខែដើមឆ្នាំ២០២៤




*ប្រភព÷ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)*

តារាង ៤៖ ស្ថានភាពវិនិយោគសរុប ឆ្នាំ២០២១, ២០២២, ២០២៣, និង ២០២៤

| អំឡុងពេល | ចំនួនគម្រោងវិនិយោគ | ទំហំទុនវិនិយោគ (លានដុល្លារ) | ការបង្កើតការងារថ្មី |
|---|---|---|---|
| ៦ខែ ឆ្នាំ២០២១ | 87 | 2,970 | 12,600 |
| ៦ខែ ឆ្នាំ២០២២ | 98 | 2,999 | 70,730 |
| ៦ខែ ឆ្នាំ២០២៣ | 113 | 1,106 | 122,181 |
| ៦ខែ ឆ្នាំ២០២៤ | 190 | 3,258 | 168,572 |

*ប្រភព÷ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)*

## ១.៥. វិស័យទេសចរណ៍ក្នុងតំបន់អង្គរ / Angkor Park Tourism

ក្នុងខែមិថុនា ឆ្នាំ២០២៤ ចំនួនភ្ញៀវទេសចរបរទេសទិញប័ណ្ណពីគ្រឹះស្ថានអង្គរមានការថមថយ។ យោងតាមទិន្នន័យការលក់ប័ណ្ណចូលទស្សនារមណីយដ្ឋានអង្គររបស់សហគ្រាសអង្គរ បានបង្ហាញថា ឧទ្យានអង្គរបានទទួលភ្ញៀវបរទេសប្រមាណ ៤៩ ៦៩២ នាក់ ដោយគិតជាប្រាក់ចំណូល បានប្រមាណ ២,១៥ លានដុល្លារ។ បើធៀបនឹងខែមុន ចំនួនភ្ញៀវទេសចរបរទេសទិញប័ណ្ណ និងចំណូលពីលក់ប័ណ្ណថយ ២,៣៣% និង ៦,០៥% រៀងគ្នា។ ការធ្លាក់ចុះនេះ គឺបណ្តាលមកពីកត្តារដូវកាល ដូចជាការចាប់ផ្តើមថយចុះនៃការធ្វើដំណើរបែបទេសចរណ៍ (Low-Season) ដែលធ្វើឱ្យចំនួនភ្ញៀវទេសចរបរទេសអាចនឹងបន្តធ្លាក់រហូតដល់ខែតុលា។

បើធៀបទៅនឹងខែមិថុនា ឆ្នាំ ២០២៣ ចំនួនភ្ញៀវទេសចរ និងចំណូលពីការលក់ប័ណ្ណទស្សនារមណីយដ្ឋានអង្គរ បានកើន ២១,១៦% និង ១៨,៧២% រៀងគ្នា។ ជាលទ្ធផល ក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២៤នេះ រមណីយដ្ឋានអង្គរ បានទទួលភ្ញៀវទេសចរបរទេសសរុបប្រមាណ ៥២១,៩៥០នាក់ កើន ៣៥,៣០% ធៀបនឹង៦ខែដើមឆ្នាំ២០២៣។

ក្រាហ្វិក ១០៖ ចំនួនភ្ញៀវបរទេសទិញប័ណ្ណទស្សនារមណីយដ្ឋានអង្គរ ចំណូលពីការលក់ប័ណ្ណ




*ប្រភព៖ គ្រឹះស្ថានអង្គរ*

## ១.៤. ស្ថានភាពសំណង់ / Construction

ក្នុងខែមិថុនា ឆ្នាំ២០២៤ គម្រោងដែលទទួលបានការអនុញ្ញាតសាងសង់សរុប ៣១២ គម្រោង ដែលមានផ្ទៃក្រឡាសរុប ១ ៨៦៨ ពាន់ម៉ែត្រការ៉េ និងបានប្រើប្រាស់ទុនក្នុងទំហំ ៧២៥,០ លានដុល្លារ។ បើធៀបនឹងខែមុន ចំនួនគម្រោងសាងសង់ និងផ្ទៃក្រឡាសាងសង់ កើន ៣៥,០% (ស្មើនឹង នឹង ៨១ គម្រោង)និង ៣៦,១% រៀងគ្នា ខណៈដែលទុនសាងសង់មានការធ្លាក់ប្រមាណ ២,០%។ ក្នុងគម្រោងសំណង់ទាំងអស់មាន សំណង់លំនៅដ្ឋាន ២៥១ គម្រោង សំណង់ឧស្សាហកម្ម ២៧ គម្រោង សំណង់ពាណិជ្ជកម្ម ១៥ គម្រោង សំណង់ទេសចរណ៍ ៥ គម្រោង និងសំណង់សាធារណៈ ១៤ គម្រោង។

យោងតាមទិន្នន័យ ក្នុងរយៈពេល៦ខែដើមឆ្នាំ២០២៤ គម្រោងទទួលបានការអនុញ្ញាតសាងសង់សរុប មានចំនួន ១ ៦៤២ គម្រោង ក្នុងនោះ មានគម្រោងលំនៅដ្ឋាន ១ ៣៤៦ គម្រោង (មានបុរីចំនួន ១ ២៩៨ គម្រោង និងខុនដូ ៤៨ គម្រោង), សំណង់ឧស្សាហកម្ម ១១៥ គម្រោង, សំណង់ពាណិជ្ជកម្ម ១០៥ គម្រោង, សំណង់ទេសចរណ៍ ២៦ គម្រោង, សំណង់សាធារណៈ ៤៩ គម្រោង, និងសំណង់វិនិយោគ ១ គម្រោង។

ក្រាហ្វិក ១១៖ ផ្ទៃក្រឡាសាងសង់សរុបនិងអត្រាបម្រែបម្រួលក្នុងរយៈពេល ៦ខែ ចាប់គិតពី ២០២០-២០២៤




ក្រាហ្វិក ១២៖ ចំនួនសំណើសាងសង់សរុបនិងអត្រាបម្រែបម្រួលក្នុងរយៈពេល ៦ខែ ចាប់គិតពី ២០២០-២០២៤



ក្រាហ្វិក ១៣៖ ចំនួនគម្រោងនិងក្រឡាផ្ទៃ (ម៉ែត្រការ៉េ)




*ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*

## ២. និន្នាការថ្លៃទំនិញសំខាន់ៗ / Commodity prices

### ២.១. ថ្លៃប្រេងឥន្ធនៈ

ក្នុងខែមិថុនា ឆ្នាំ២០២៤ ថ្លៃប្រេងឥន្ធនៈក្នុងស្រុកជាមធ្យម ស្ថិតក្នុងរង្វង់ ៤ ១៧៧ រៀល/លីត្រ ថយ ១,៨% ធៀបនឹងខែមុន ក្នុងនោះ ប្រេងសាំងធម្មតាថ្លៃ ៤ ១៦៧ រៀល/លីត្រ (ថយ ៣,៥%) និង ប្រេងម៉ាស៊ូតថ្លៃ ៤ ០៦៧ រៀល/លីត្រ (ដូចខែមុន)។ គួរកត់សម្គាល់ដែរថា ក្នុងរយៈពេល ២ខែចុងក្រោយនេះ ថ្លៃប្រេងឥន្ធនៈក្នុងស្រុក មាននិន្នាការថយចុះតិចតួច ដែលស្របគ្នានឹងការធ្លាក់ថ្លៃប្រេងនៅលើទីផ្សារអន្តរជាតិដែរ។ យ៉ាងណាមិញ ធៀបនឹងខែមិថុនា ឆ្នាំ២០២៣ ថ្លៃប្រេងឥន្ធនៈក្នុងស្រុក កើន ១,៩% និង ក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២៤ ថ្លៃប្រេងឥន្ធនៈក្នុងស្រុក កើន ០,១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៣ ក្នុងនោះ ថ្លៃប្រេងសាំង កើន ០,៥% ប៉ុន្តែ ថ្លៃប្រេងម៉ាស៊ូត ថយ ០,៤%។

ក្នុងខែមិថុនា ឆ្នាំ២០២៤ ថ្លៃប្រេងឆៅជាមធ្យម នៅលើទីផ្សារអន្តរជាតិ ស្ថិតក្នុងរង្វង់ ៨១,២ ដុល្លារ/បារ៉ែល ថយ ០,៣% ធៀបនឹងខែមុន ក្នុងនោះ ប្រេងឆៅ Dubai ថ្លៃ ៨២,២ ដុល្លារ/បារ៉ែល (ថយ ១,៦%) ខណៈដែល ប្រេងឆៅ Brent ថ្លៃ ៨២,៦ ដុល្លារ/បារ៉ែល (កើន ០,៧%) និង ប្រេងឆៅ WTI ថ្លៃ ៧៨,៩ ដុល្លារ/បារ៉ែល (កើន ០,១%)។ ទោះជាមានការថយចុះតិចតួចធៀបនឹងខែមុន ប៉ុន្តែ ធៀបនឹងខែមិថុនា ឆ្នាំ២០២៣ ថ្លៃប្រេងឆៅជាមធ្យម កើន ១០,៨% និង ក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២៤ ថ្លៃប្រេងឆៅជាមធ្យម កើន ៥,៥% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៣។




*ប្រភព៖ ក្រសួងពាណិជ្ជកម្ម*




*ប្រភព៖ ធនាគារពិភពលោក (The Pink Sheet)*

### ២.២. ថ្លៃអង្ករ៖

នៅលើទីផ្សាររាជធានីភ្នំពេញ ក្នុងខែមិថុនា ឆ្នាំ២០២៤ ថ្លៃអង្ករជាមធ្យម ស្ថិតក្នុងរង្វង់ ៣ ៤៥៩ រៀល/គ.ក្រ ថយ ០,៥% ធៀបនឹងខែមុន ក្នុងនោះ អង្ករផ្កាម្លិះថ្លៃ ៤ ០៤៧ រៀល/គ.ក្រ (ថយ ០,៣%) និងអង្ករនាងមិញថ្លៃ ២ ៩៧៦ រៀល/គ.ក្រ (ថយ ២,៩%)។ ផ្អែកតាមការតាមដាន ថ្លៃអង្ករជាមធ្យមក្នុងខែមិថុនា ឆ្នាំ២០២៤ ប្រហាក់ប្រហែលនឹងខែមុនដែរ ប៉ុន្តែបើធៀបនឹងខែមិថុនា ឆ្នាំ២០២៣ ថ្លៃអង្ករជាមធ្យម កើន ៨,៣% និង ក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២៤ ថ្លៃអង្ករជាមធ្យម កើនឡើង ក្នុងរង្វង់ ១១,៤% ដែលកំណើននេះ អាចបណ្តាលមកពីបញ្ហាអាកាសធាតុ ដែលបានកាត់បន្ថយការផលិត ស្របពេលដែល តម្រូវការក្រៅប្រទេសមានការកើនឡើង។

នៅលើទីផ្សារអន្តរជាតិ ក្នុងខែមិថុនា ឆ្នាំ២០២៤ ថ្លៃអង្ករអន្តរជាតិ ស្ថិតក្នុងរង្វង់ ៦០០,៥ ដុល្លារ/តោន កើន ០,៣% ធៀបនឹងខែមុន ក្នុងនោះ អង្ករថៃប្រភេទបាក់៥% ថ្លៃ ៦៣២,០ ដុល្លារ/តោន (កើន ០,៦%), អង្ករថៃប្រភេទបាក់ ២៥% ថ្លៃ ៥៩៥,០ ដុល្លារ/តោន (កើន ០,៣%), អង្ករថៃប្រភេទ A1 ថ្លៃ ៦១៣,៣ ដុល្លារ/តោន (កើន ១,១%)។ ជាមួយគ្នានេះ បើធៀបនឹងខែមិថុនា ឆ្នាំ២០២៣ ថ្លៃអង្ករជាមធ្យម កើន ១៩,៣% និង ក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២៤ ថ្លៃអង្ករជាមធ្យម កើន ២៤,៩%។ តាមរយៈការសង្កេត ថ្លៃអង្ករអន្តរជាតិ មាននិន្នាការកើនឡើងខ្លាំង ក្នុងឆ្នាំ២០២៣

ជាពិសេសនៅពេលដែលប្រទេសឥណ្ឌា ផ្អាកការផ្គត់ផ្គង់អង្ករទៅកាន់ទីផ្សារពិភពលោក ស្របពេលដែល ប្រទេសផលិតស្រូវអង្ករដទៃទៀត បានរងផលប៉ះពាល់ពីបាតុភូតធម្មជាតិ អែលនីណូ (El Nino) ។

**ក្រាហ្វិក ១៦៖ និន្នាការថ្លៃអង្ករស្តង់ដារលើទីផ្សារកម្ពុជា**




*ប្រភព៖ ការចុះស្រង់ថ្លៃទំនិញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋានគោលនយោបាយពីផ្សារចំនួន ៤ ក្នុងរាជធានីភ្នំពេញ*

**ក្រាហ្វិក ១៧៖ និន្នាការថ្លៃអង្ករស្តង់ដារលើទីផ្សារអន្តរជាតិ**




*ប្រភព៖ ធនាគារពិភពលោក (The Pink Sheet)*

**************

# ៣. ឧបសម្ព័ន្ធ

## ៣.១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia Economic Trends

### ៣.១.១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index

តារាង ៣.១.១.៖ ការប្រែប្រួលសន្ទស្សន៍ថ្លៃនៃក្រុមទំនិញទាំង ១២ ក្នុងខែមិថុនា ឆ្នាំ២០២៤ គិតជា%

| បរិយាយ | ២០២៣ | | ២០២៤ | | ២០២៣ | | ២០២៤ | |
|---|---|---|---|---|---|---|---|---|
| | ធៀបនឹងខែមុន (MoM) | | | | ធៀបនឹងឆ្នាំមុន (YoY) | | | |
| | ឧសភា | មិថុនា | ឧសភា | មិថុនា | ឧសភា | មិថុនា | ឧសភា | មិថុនា |
| មុខទំនិញគ្រប់មុខ | 0.2% | 0.4% | 0.8% | 0.0% | 0.5% | 0.1% | 1.1% | 0.7% |
| ១. អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | 0.5% | 0.5% | 1.4% | -0.3% | 2.2% | 2.0% | 1.6% | 0.8% |
| ២. ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | 1.1% | 0.2% | 0.1% | 0.3% | 1.9% | 1.9% | 0.0% | 0.1% |
| ៣. សម្លៀកបំពាក់ និងស្បែកជើង | 0.5% | 0.5% | 1.4% | 0.5% | 2.1% | 2.1% | 2.5% | 2.5% |
| ៤. ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈដទៃទៀត | 0.4% | 0.2% | 0.4% | 0.1% | -1.2% | -1.3% | 0.1% | 0.0% |
| ៥. គ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់ និងការថែទាំ | 0.2% | 0.2% | 0.3% | 0.1% | 1.0% | 1.0% | 0.6% | 0.5% |
| ៦. សុខាភិបាល | 0.4% | 0.3% | 0.3% | 2.3% | 0.1% | 0.0% | 0.5% | 2.6% |
| ៧. ការដឹកជញ្ជូន | -2.0% | 0.0% | -2.4% | 0.0% | -8.7% | -10.9% | -0.4% | -0.3% |
| ៨. គមនាគមន៍ | 0.0% | 0.1% | 0.1% | -0.1% | -0.1% | -0.1% | 0.0% | -0.2% |
| ៩. ការកំសាន្ត និងវប្បធម៌ | 0.4% | 0.4% | 0.4% | 0.1% | 2.1% | 1.9% | 0.4% | 0.0% |
| ១០. ការសិក្សា | 0.0% | 0.4% | 0.4% | 0.0% | 1.2% | 1.6% | 2.9% | 2.5% |
| ១១. ភោជនីយដ្ឋាន | -0.1% | 0.6% | 0.6% | 0.6% | -0.6% | -1.3% | 0.8% | 0.7% |
| ១២. ទំនិញ និងសេវាកម្មផ្សេងៗ | 0.3% | 0.3% | 0.3% | 0.1% | 1.3% | 1.4% | 0.5% | 0.4% |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (NIS)*
*សម្គាល់៖ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

## ៣.១.២. វិស័យពាណិជ្ជកម្ម / Trade

តារាង ៣.១.២.៖ ការនាំចេញ និងការនាំចូលតាមមុខទំនិញសំខាន់ៗប្រចាំខែមិថុនា ឆ្នាំ២០២៤ (លានដុល្លារអាម៉េរិក)

| សូចនាករ | ២០២២ ៦ខែ | ២០២៣ ៦ខែ | ២០២៤ ៦ខែ | ២០២៤ | | | Δ% | | |
|---|---|---|---|---|---|---|---|---|---|
| | | | | មេសា | ឧសភា | មិថុនា | ខែមុន | ឆ្នាំមុន | ឆ្នាំមុន (៦ខែ) |
| តម្លៃនាំចេញសរុប (I) | 11,379 | 11,464 | 12,428 | 1,768 | 2,098 | 2,246 | 7.0% | -1.6% | 8.4% |
| តម្លៃនាំចេញសរុប (ដកមាសចេញ) | 11,245 | 10,924 | 12,296 | 1,744 | 2,067 | 2,223 | 7.5% | 1.4% | 12.6% |
| វាយនភណ្ឌ និងស្បែកជើង | 6,469 | 5,267 | 6,157 | 809 | 1188 | 1262 | 6.3% | 4.1% | 16.9% |
| កង់ | 456 | 279 | 162 | 30 | 32 | 31 | -2.5% | -36.1% | -41.9% |
| អង្ករ | 204 | 229 | 253 | 54 | 35 | 30 | -13.0% | -19.6% | 10.3% |
| ដំឡូងមី | 463 | 404 | 500 | 34 | 28 | 15 | -45.8% | -21.5% | 23.8% |
| ជ័រកៅស៊ូ | 182 | 164 | 229 | 24 | 33 | 44 | 30.8% | 41.5% | 40.0% |
| ទំនិញផ្សេងៗ | 3,471 | 4,581 | 4,996 | 793 | 751 | 840 | 11.9% | -0.3% | 9.0% |
| តម្លៃនាំចូលសរុប (II) | 15,865 | 12,229 | 13,960 | 2,438 | 2,602 | 2,530 | -2.8% | 19.3% | 14.2% |
| តម្លៃនាំចូលសរុប (ដកមាសចេញ) | 13,011 | 12,229 | 13,797 | 2,430 | 2,602 | 2,530 | -2.8% | 19.3% | 12.8% |
| ក្រណាត់ | 2,724 | 2,236 | 2,710 | 500 | 597 | 484 | -18.9% | 19.8% | 21.2% |
| គ្រឿងសំណង់ | 983 | 921 | 1,136 | 184 | 229 | 210 | -8.3% | 24.5% | 23.3% |
| យានយន្ត | 683 | 527 | 582 | 97 | 109 | 98 | -10.2% | 46.3% | 10.4% |
| ប្រេងឥន្ធនៈ | 1,312 | 1,180 | 1,529 | 276 | 290 | 242 | -16.4% | 21.3% | 29.6% |
| ទំនិញផ្សេងៗទៀត | 7,309 | 7,365 | 7,839 | 1,373 | 1,377 | 1,496 | 8.7% | 16.8% | 6.4% |
| តុល្យភាពពាណិជ្ជកម្ម (I-II) | -4,486 | -765 | -1,531 | -670 | -504 | -285 | | | |

*ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*

*សម្គាល់៖ ក្នុងតារាង (,)ស្មើកាត់ខ្ទង់ និង (.)ស្មើក្បៀស*

## ៣.១.៣. ស្ថានភាពវិនិយោគ / Investment

តារាង ៣.១.៣.៖ ស្ថានភាពវិនិយោគក្នុងខែមិថុនា ឆ្នាំ២០២៤

| សូចនាករ | ឯកតា | ២០២៣ | ២០២៣ ៦ខែ | ២០២៤ ៦ខែ | ២០២៤ | | | Δ% | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | មេសា | ឧសភា | មិថុនា | ខែមុន | ឆ្នាំមុន | ឆ្នាំមុន (៦ខែ) |
| ចំនួនគម្រោង | គម្រោង | 268 | 113 | 190 | 22 | 25 | 37 | 12 | -1 | 77 |
| ចំនួនទុនវិនិយោគ | លាន($) | 4,927.6 | 1,105.7 | 3,257.9 | 309.57 | 246.30 | 498.44 | 102.4% | 9.1% | 194.7% |
| ចំនួនការងារបង្កើត | នាក់ | 307,553 | 122,181 | 168,572 | 23,382 | 15,139 | 22,951 | 51.6% | -41.8% | 38.0% |

*ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*

*សម្គាល់៖ ១) *គិតជាចំនួនគម្រោង ២)ក្នុងតារាង (,)ស្មើកាត់ខ្ទង់ និង (.)ស្មើក្បៀស*

## ៣.១.៤. ស្ថានភាពទេសចរណ៍ / Tourism

| តារាង ៣.១.៤.៖ ចំនួនភ្ញៀវអន្តរជាតិក្នុងខែមិថុនា ឆ្នាំ២០២៤ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សូចនាករ | ឯកតា | ២០២៣ | ២០២៣ | ២០២៤ | ២០២៤ | | | Δ% | | |
| | | | ៦ខែ | ៦ខែ | មេសា | ឧសភា | មិថុនា | ខែមុន | ឆ្នាំមុន | ឆ្នាំមុន (៦ខែ) |
| ទេសចរបរទេសចូលមណ្ឌលអង្គរ | ពាន់នាក់ | 798.1 | 385.77 | 521.95 | 73.85 | 50.88 | 49.69 | -2.33% | 21.16% | 35.30% |
| ចំណូលពីសំបុត្ររបស់គ្រឹះស្ថានអង្គរ | លាន($) | 37.199 | 17.88 | 24.36 | 3.38 | 2.29 | 2,15 | -6.05% | 18.72% | 36.25% |

*ប្រភព៖ ក្រសួងទេសចរណ៍*

*សម្គាល់៖ ក្នុងតារាង (,)ស្មើកាត់ខ្ទង់ និង (.)ស្មើក្បៀស*

## ៣.១.៥. ស្ថានភាពសំណង់ / Construction

| តារាង ៣.១.៥.៖ ស្ថានភាពសំណង់ក្នុងខែមិថុនា ឆ្នាំ២០២៤ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សូចនាករ | ឯកតា | ២០២៣ | ២០២៣ | ២០២៤ | ២០២៤ | | | Δ % | | |
| | | | ៦ខែ | ៦ខែ | មេសា | ឧសភា | មិថុនា | ខែមុន | ឆ្នាំមុន | ឆ្នាំមុន (៦ខែ) |
| សរុបចំនួនគម្រោង * | ចំនួន | 3,207 | 1,849 | 1,642 | 269 | 231 | 312 | 81 | -74 | -207 |
| សរុបជាផ្ទៃក្រឡា | ពាន់ម២ | 13,132 | 6,817 | 6,147 | 918 | 1,373 | 1,869 | 36.1% | 44.9% | -9.8% |
| សរុបជាទឹកប្រាក់ | លាន($) | 5,461 | 2,759 | 2,536 | 285 | 740 | 725 | -2.0% | 48.3% | -8.1% |

*ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*

*សម្គាល់៖ ១) *គិតជាចំនួនគម្រោង ២)ក្នុងតារាង (,)ស្មើកាត់ខ្ទង់ និង (.)ស្មើក្បៀស*

## ៣.២. និន្នាការថ្លៃទំនិញសំខាន់ៗ / Commodity Prices

| តារាង ៣.២.១.៖ ស្ថានភាពថ្លៃទំនិញសំខាន់ៗ (ថ្លៃមធ្យមប្រចាំខែ) | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សូចនាករសំខាន់ៗ | | ឯកតា | ២០២៣ | | | ២០២៤ | | | Δ % | |
| | | | មេសា | ឧសភា | មិថុនា | មេសា | ឧសភា | មិថុនា | ខែមុន | ឆ្នាំមុន |
| ក្នុងស្រុក | សាំងធម្មតា | រៀល/លីត្រ | 4,367 | 4,133 | 4,183 | 4,467 | 4,317 | 4,167 | -3.5% | -0.4% |
| | ម៉ាស៊ូត | រៀល/លីត្រ | 4,100 | 3,867 | 3,900 | 4,183 | 4,067 | 4,067 | 0.0% | 4.3% |
| | ហ្គាស | រៀល/១៥គ.ក្រ | 76,560 | 76,850 | 76,550 | 76,450 | 76,350 | 76,250 | -0.1% | -0.4% |
| | អង្ករផ្កាម្លិះ | រៀល/គី.ក្រ | 3,674 | 3,682 | 3,812 | 3,893 | 4,059 | 4,047 | -0.3% | 6.2% |
| | អង្ករផ្កាខ្ញី | រៀល/គី.ក្រ | 2,826 | 2,813 | 3,025 | 3,370 | 3,310 | 3,355 | 1.3% | 10.9% |
| | អង្ករនាងមិញ | រៀល/គី.ក្រ | 2,674 | 2,671 | 2,750 | 3,000 | 3,064 | 2,976 | -2.9% | 8.2% |
| អន្តរជាតិ | Average Oil Price | រៀល/គី.ក្រ | 82.46 | 74.12 | 73.26 | 88.01 | 81.45 | 81.21 | -0.3% | 10.8% |
| | Brent | ដុល្លារ/បារ៉ែល | 84.11 | 75.70 | 74.89 | 90.05 | 82.00 | 82.56 | 0.7% | 10.2% |
| | Dubai | ដុល្លារ/បារ៉ែល | 83.83 | 75.08 | 74.67 | 89.39 | 83.53 | 82.17 | -1.6% | 10.0% |
| | WTI | ដុល្លារ/បារ៉ែល | 79.44 | 71.59 | 70.23 | 84.59 | 78.81 | 78.89 | 0.1% | 12.3% |
| | អង្ករថៃ (៥%) | ដុល្លារ/បារ៉ែល | 501.00 | 510.00 | 514.00 | 592.00 | 628.00 | 632.00 | 0.6% | 23.0% |
| | អង្កររៀតណាម (៥%) | ដុល្លារ/តោន | 455.10 | 470.53 | 508.24 | 571.50 | 567.97 | 561.63 | -1.1% | 10.5% |
| | អង្ករថៃ (២៥%) | ដុល្លារ/តោន | 490.00 | 495.00 | 496.00 | 564.00 | 593.00 | 595.00 | 0.3% | 20.0% |
| | អង្ករថៃ A.1 (100%) | ដុល្លារ/តោន | 482.88 | 492.68 | 495.75 | 577.95 | 606.47 | 613.30 | 1.1% | 23.7% |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (NIS), ក្រសួងពាណិជ្ជកម្ម, World Bank, អ.គ.ឋ.*

## ៣.២.២ ស្ថានភាពថ្លៃប្រេងឥន្ធនៈនៅប្រទេសកម្ពុជា

**តារាង ៣.២.២ ថ្លៃលក់រាយប្រេងឥន្ធនៈនៅប្រទេសកម្ពុជា (ថ្លៃមធ្យមប្រចាំខែ និងប្រចាំឆ្នាំ)**

| ឈ្មោះទំនិញ | ឯកតា | ថ្លៃលក់រាយ (ថ្លៃមធ្យមប្រចាំឆ្នាំ) | | | | | | ថ្លៃលក់រាយ (ថ្លៃមធ្យមប្រចាំខែ) ៦ខែចុងក្រោយ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ៦ខែ ដើមឆ្នាំ ២០២៤ | មករា ២០២៤ | កុម្ភៈ ២០២៤ | មិនា ២០២៤ | មេសា ២០២៤ | ឧសភា ២០២៤ | មិថុនា ២០២៤ |
| សាំងធម្មតា | ៛/លីត្រ | 3,623 | 3,000 | 3,888 | 4,800 | 4,326 | 4,289 | 4,167 | 4,333 | 4,300 | 4,467 | 4,317 | 4,167 |
| ប្រេងម៉ាស៊ូត | ៛/លីត្រ | 3,504 | 2,768 | 3,508 | 5,115 | 4,299 | 4,150 | 4,133 | 4,267 | 4,167 | 4,183 | 4,067 | 4,067 |
| ប្រេងឥន្ធនៈជាមធ្យម | ៛/លីត្រ | 3,564 | 2,884 | 3,698 | 4,958 | 4,312 | 4,220 | 4,150 | 4,300 | 4,233 | 4,325 | 4,192 | 4,117 |

**ការប្រែប្រួលថ្លៃប្រេងឥន្ធនៈនៅប្រទេសកម្ពុជា (រៀល/លីត្រ) និង (%)**

| ឈ្មោះទំនិញ | ឯកតា | ការប្រែប្រួលថ្លៃប្រេងឥន្ធនៈប្រចាំឆ្នាំ (រៀល/លីត្រ) និង (%) | | | | | | ការប្រែប្រួលថ្លៃប្រេងឥន្ធនៈប្រចាំខែ (រៀល/លីត្រ) និង (%) (៦ខែចុងក្រោយ) | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ៦ខែ ដើមឆ្នាំ ២០២៤ | មករា ២០២៤ | កុម្ភៈ ២០២៤ | មិនា២០២៤ | មេសា ២០២៤ | ឧសភា ២០២៤ | មិថុនា ២០២៤ |
| សាំងធម្មតា | ៛/លីត្រ | - | - 623 | +888 | +913 | -474 | - 36 | -33 | +167 | -33 | +167 | -150 | -150 |
| | % | - | - 17.19% | +29.58% | +23.47% | -9.88% | - 0.84% | -0.79% | +4.0% | - 0.77% | +3.88% | -3.36% | -3.47% |
| ប្រេងម៉ាស៊ូត | ៛/លីត្រ | - | - 736 | +740 | +1,607 | -817 | - 149 | -50 | +133 | -100 | +17 | -117 | - |
| | % | - | -21.01% | +26.75% | +45.80% | -15.96% | -3.46% | -1.20% | +3.23% | - 2.34% | +0.40% | -2.79% | - |
| ប្រេងឥន្ធនៈជាមធ្យម | ៛/លីត្រ | - | -680 | +814 | +1,260 | -645 | - 92 | -42 | +150 | -67 | +92 | -133 | -75 |
| | % | - | -19.07% | +28.22% | +34.06% | -13.02% | -2.14% | - 0.99% | +3.61% | -1.55% | +2.17% | -3.08% | -1.79% |

*ប្រភព៖ ក្រសួងពាណិជ្ជកម្ម*

## ៣.២.៣ ស្ថានភាពថ្លៃឆៅនៅលើទីផ្សារអន្តរជាតិ

| តារាង ៣.២.៣ ថ្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ (ថ្លៃមធ្យមប្រចាំខែ និងប្រចាំឆ្នាំ) | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះទំនិញ | ឯកតា | ថ្លៃមធ្យមប្រចាំឆ្នាំ | | | | | | ថ្លៃមធ្យមប្រចាំខែ ៦ខែចុងក្រោយ | | | | | |
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ៦ខែ ដើមឆ្នាំ ២០២៤ | មករា ២០២៤ | កុម្ភៈ ២០២៤ | មិនា ២០២៤ | មេសា ២០២៤ | ឧសភា ២០២៤ | មិថុនា ២០២៤ |
| ប្រេងឆៅ (Brent) | $/បារ៉ែល | 64.03 | 42.30 | 70.44 | 99.82 | 82.62 | 84.01 | 77.67 | 80.55 | 83.55 | 88.01 | 81.45 | 81.21 |
| ប្រេងឆៅ (WTI) | $/បារ៉ែល | 63.18 | 42.17 | 68.81 | 97.05 | 81.98 | 83.31 | 80.23 | 83.76 | 85.45 | 90.05 | 82.00 | 82.56 |
| ប្រេងឆៅ (Dubai) | $/បារ៉ែល | 57.01 | 39.31 | 67.96 | 94.43 | 77.67 | 78.90 | 78.86 | 81.18 | 84.70 | 89.39 | 83.53 | 82.17 |
| ប្រេងឆៅជាមធ្យម | $/បារ៉ែល | 61.41 | 41.26 | 69.07 | 97.10 | 80.76 | 82.07 | 73.93 | 76.70 | 80.49 | 84.59 | 78.81 | 78.89 |

| ការប្រែប្រួលថ្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ (ដុល្លារ/បារ៉ែល) និង (%) | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះទំនិញ | ឯកតា | ការប្រែប្រួលថ្លៃប្រេងឥន្ធនៈប្រចាំឆ្នាំ (ដុល្លារ/បារ៉ែល) និង (%) | | | | | | ការប្រែប្រួលថ្លៃប្រេងឥន្ធនៈប្រចាំខែ (ដុល្លារ/បារ៉ែល) និង (%) (៦ខែចុងក្រោយ) | | | | | |
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ៦ខែ ដើមឆ្នាំ ២០២៤ | មករា ២០២៤ | កុម្ភៈ ២០២៤ | មិនា ២០២៤ | មេសា ២០២៤ | ឧសភា ២០២៤ | មិថុនា ២០២៤ |
| ប្រេងឆៅ (Brent) | $/បារ៉ែល | - | -21.73 | +28.14 | +29.38 | -17.21 | +1.39 | +2.37 | +2.88 | +3.00 | +4.47 | -6.57 | -0.24 |
| | % | - | -33.94% | +66.53% | +41.71% | -17.24% | +1.68% | +0.03 | +3.70% | +3.72% | +5.35% | -7.46% | -.29% |
| ប្រេងឆៅ (WTI) | $/បារ៉ែល | - | -21.01 | +26.64 | +28.24 | -15.07 | +1.32 | +1.64 | +3.54 | +1.68 | +4.61 | -8.06 | +0.56 |
| | % | - | -33.26% | +63.18% | +41.05% | -15.53% | +1.61% | +0.02 | +4.41% | +2.01% | +5.39% | -8.95% | +.68% |
| ប្រេងឆៅ (Dubai) | $/បារ៉ែល | - | -17.71 | +28.66 | +26.47 | -16.76 | +1.23 | +1.85 | +2.32 | +3.52 | +4.69 | -5.86 | -1.36 |
| | % | - | -31.05% | +72.90% | +38.94% | -17.75% | +1.59% | +0.03 | +2.94% | +4.34% | +5.54% | -6.56% | -1.63% |
| ប្រេងឆៅជាមធ្យម | $/បារ៉ែល | - | -20.15 | +27.81 | +28.03 | -16.35 | +1.32 | +1.95 | +2.77 | +3.79 | +4.10 | -5.78 | +0.08 |
| | % | - | -32.81% | +67.41% | +40.58% | -16.83% | +1.63% | +0.03 | +3.75% | +4.94% | +5.09% | -6.83% | +.10% |

*ប្រភព៖ ធនាគារពិភពលោក (The Pink Sheet)*